និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ និងប្រការ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាព តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីស្តីទី

ឧបនាយករដ្ឋមន្ត្រី

**ស ខេង**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០០

## សេចក្តីសំរេច លេខ ៣៩ សសរ

## ស្តីពី

## ការបង្កើតក្រុមការងារជួសជុលសាងសង់ផ្លូវ

## ទៅកាន់មជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញ កម្ពុជា-ថៃ ពូនភ្នំ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសភាពការណ៍ចាំបាច់ជាក់ស្តែង

## សំរេច

**ប្រការ ១** : បង្កើតក្រុមការងារជួសជុលសាងសង់ផ្លូវ ចាប់ពីផ្លូវជាតិលេខ៥ ទៅកាន់មជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញ កម្ពុជា-ថៃ ពូនភ្នំ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **ជា សុផារ៉ា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ជា ប្រធាន

២-ឯកឧត្តម **អ៊ុន ឈន** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជា សមាជិក

៣-ឯកឧត្តម **ខ្លឹ សារិន** អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជា សមាជិក

៤-លោក **តូច ចាន់កុសល** អគ្គនាយករងទី១សាធារណការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ជា សមាជិក

៥-លោក **ឃុយ ឃៀង** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជា សមាជិក

ប្រការ ២ : ក្រុមការងារនេះ ត្រូវចាប់ផ្តើមបើកការដឹកនាំអនុវត្តការផ្តល់ផ្លាកលេខសម្គាល់ផ្លូវខាងលើជាបន្ទាន់ តាមជំហានពីរខាងក្រោម :

-ជំហានទី១ - ធ្វើអោយបានរហ័សរហួន មុនថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០០ ដោយដាក់ផ្លាកក្រដាស

-ជំហានទី២ - ដាក់ និងក្រាលកៅស៊ូ ដើម្បីធានាការប្រើប្រាស់បានយូរ

ប្រការ ៣ : ក្រុមការងារនេះអាចអំពាវនាវសុំជំនួយពីសប្បុរសជន ក្នុងការផ្តល់ផ្លាក និងលេខសម្គាល់ផ្លូវខាងលើនេះបាន ។

មាត្រា ៤.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

***